Most people in poor settlements build their own houses. If all their experiences were gathered together and recorded, they would make a vast encyclopedia of low-cost design tips. In March, people from 12 poor settlements around Phnom Penh held a house design workshop. For four days, they put together their ideas to design houses that fit their needs and their wallets.

They designed houses for different plot sizes, of 30, 60 and 100 square metres. It is difficult to imagine these different plot sizes if you have always lived in a tiny hut in the city. To make this easier, they used bamboo poles to mark the corners, and then stretched cloth around the poles to "enclose" the different plots. Once the plot bounderies were in place, people could walk around "inside". This allowed everyone to get a feel for the areas. Then more cloth and poles were used to mark out the walls of their houses, the bedroom, kitchen and hall inside.

The people formed groups to talk over their ideas and to make small models of their house designs, using cardboard, paper, and glue. Some enthusiastic students from the Faculty of Architecture came to help. The students have a different way of understanding construction, and it was good to work together.

### The neighborhood of your dreams :

At the end, the models were lined up for everyone to peruse. Even poverty cannot keep people from the delight in making a home. The models were celebrations of color and pattern and ornamentation. Some models even had coconut trees in front, with tiny thermacol coconuts glued to the paper leaves.

On the last day of the workshop, more communities were invited to come see the models, and to choose the ones they liked best. Two models were chosen, one wood and one brick. Both models were designed to cost less than $2,000.

### Wood or Brick?

The SUPF survey shows that 95% of the people in Phnom Penh's poor settlements live in wood or bamboo houses. Only 5% live in brick houses. People in Cambodia are experts in building with wood, but they also understand the problems of wood.

- Traditional wood houses on stilts are a sensible design for Cambodia's hot weather and rain. But they work best when completely separate, on large plots. This is not possible in crowded places in the city.
- Right now, wood houses are much cheaper than brick, but the forests are disappearing and the price of wood is going up.
- On small rowhouse plots, brick houses make sound-proof common walls. They also reduce the danger of fast-spreading fires.



*Sarani wants to open a perfume shop in front of the rowhouse she designed. Tho Thary laid out her house with room for a garden. Chamnan's idea was to build a "shell house", to keep costs down, and then add finishes later. A lot of ideas were tested "on the ground" during the house-design workshop last March.*

# សិក្ខាសាលាពីការគូសវាសប្លង់ផ្ទះ :

មនុស្សភាគច្រើននៅ សហគមន៍អ្នកក្រីក្រសង់ផ្ទះរបស់គេដោយខ្លួនគេផ្ទាល់។ គ្រប់បទពិសោធន៍ របស់គេអាចចងក្រងបានជាសៀវភៅដ៏ធំ ស្តីពីលំនៅដ្ឋានដែលមានតំលៃទាប។ នាខែមិនាមនុស្សចំនួន ១២សហគមន៍ នៅទូទាំងក្រុងភ្នំពេញបានធ្វើសិក្ខាសាលាមួយពីការធ្វើប្លង់ផ្ទះ។ ក្នុងរយៈពេលបួនថ្ងៃនេះ ពួកគេបានបញ្ចេញ នូវគំនិតពីការធ្វើប្លង់ផ្ទះ នឹងស្រមៃទៅដល់ផ្ទះដែលគេចង់នៅ ។

គេបានធ្វើការសិក្សាអំពីផ្ទះដែលមានតំលៃថោក នៅដីបរិវេណដីឡូត៍បីប្រភេទគឺ ៣០ម៉ែត្រការ៉េ, ៦០ម៉ែត្រការ៉េ, ១០០ម៉ែត្រការ៉េ ។ ដំបូងមានការលំបាកសំរាប់ធ្វើការស្រមៃដល់ទំហំដី ប៉ុន្តែគេបានយកបង្គោល មកបោះទៅតាមទំហំដីឡូត៍ដែលគេចង់បាន ហើយយកក្រណាត់មករុំ ពទ្ធ័ពីក្រៅ ធ្វើជាជញ្ជាំងដើម្បីបញ្ជាក់ទំហំផ្ទះ នៅពេលដែលគេបានធ្វើហើយ អ្នកទាំងនោះចាប់ផ្តើមដើរពេញក្នុងនោះគិតពីក្រលាផ្ទៃដែលគេចង់បាន បន្ទាប់មកគេបន្ត គិតពីទីតាំងនានា ចង្ក្រាន . . . ។

ក្រោយមកគេរៀបចំជាក្រុមដើម្បីបញ្ចេញគំនិតរបស់គេរៀងៗខ្លួនហើយប្រែក្លាយ វាមកជាផ្ទះគំរូតូចៗ អំពីក្រដាសវិញម្តង ដោយមានការចូលរួមគំនិតរបស់និស្សិតស្ថាបត្យកម្មផងដែរ។ ក្រោយមកផ្ទះគំរូនោះបានធ្វើហើយ រួចរាល់យ៉ាងស្អាតល្អ ដោយមានការលំអរដោយដើមដូងដើមឈើនានាដែលគេបានរចនាលំអរក្នុងបរិវេណដីឡូត៍នោះ ។

នៅថ្ងៃចុងក្រោយនៃសិក្ខាសាលា សហគមន៍ជាច្រើនត្រូវបានអញ្ជើញអោយ ចូលរួមទស្សនាផ្ទះគំរូ នោះហើយនឹងជ្រើសរើស យកផ្ទះណាមួយដែលគេពេញចិត្តបំផុត ពេលនោះគេជ្រើសរើសបានផ្ទះគំរូ ២ ដែលធ្វើពីឈើ មួយទៀតពីថ្ម ហើយផ្ទះនិមួយៗនឹងត្រូវចំណាយអស់តិចជាង ២០០០ដុល្លា ។

### ឈើ ឬ ថ្ម?

ការធ្វើអង្កេតរបស់ស.ស.អ.ក បានបង្ហាញថា៩៥ភាគរយនៃប្រជាជននៅភ្នំពេញ អ្នកក្រីក្ររស់នៅ ក្នុងផ្ទះធ្វើពីឬស្សីឬឈើ ៥ភាគរយជាថ្ម ប្រជាជនកម្ពុជាមានការយល់ដឹងពីរចនាសម្ពន្ធ័ ផ្ទះឈើនឹងយល់បាន ពីបញ្ហារបស់វា ។

- ផ្ទះឈើបូរាណដែលសង់ផុតពីដី ត្រូវបានគេស្គាល់ច្បាស់នៅកម្ពុជាដែលជាប្រទេសក្តៅ -សើម។ ហើយ ផ្ទះឈើរបៀបនោះវាពុំមាន លក្ខណៈល្អប៉ុន្មានទេ សំរាប់តំបន់ចង្អៀតៗក្នុងទីក្រុង។
- ឥឡូវនេះផ្ទះឈើ មានតំលៃថោកជាងផ្ទះថ្ម ប៉ុន្តែឈើវានឹងមានតំលៃថ្លៃ ។
- ផ្ទះឈើអាចអោយភ្លើងឆេះបានងាយជាងផ្ទះថ្ម

## ពិពណ៌ផ្ទះគំរូ ទីក្រុងភ្នំពេញកំពុងគិតមើលពីគំនិតរបស់ប្រជាពលរដ្ឋ

កាលពីខែ ឧសភា គំរូផ្ទះពីរដែលគំរោងឡើងដោយបណ្តាសហគមន៍នោះបានធ្វើឱ្យពួកគេមានជ័យជំនះដំបូងជាសាធារណៈ។ គំរូទាំងមូលរបស់គំរោងផ្ទះទាំងពីរនោះត្រូវសាងសង់ដោយប្រើក្រណាត់ និងឈើដែលតាំង នៅពីក្រៅការិយាល័យអង្គការ រួភច នៅក្នុងខណៈទន្លេបាសាក់ ។ មានប្រជាពលរដ្ឋមកពីសហគមន៍ ក្រីក្រជាច្រើនរាប់រយនាក់នៅ ក្នុងទីក្រុងភ្នំពេញបានមកមើលពិពណ៌នេះ ។ ប្រជាពលរដ្ឋដែលមកទស្សនា នោះបានដើរចូលកាត់តាមផ្ទះទាំងពីរនោះហើយ គេបានជជែកគ្នាជាមួយអ្នកធ្វើប្លង់ឬគំរូផ្ទះនោះទៀតផង ។ មានមន្ត្រីរាជការ និង មន្ត្រីសាលាក្រុង មន្ត្រីអង្គការក្រៅ រដ្ឋាភិបាល និងអង្គការទេសភាគីជាច្រើនក៏បានអញ្ជើញមកទស្សនាដែរ ។

ផ្ទះទាំងពីរនេះត្រូវបានធ្វើគំរោងប្លង់យ៉ាងយកចិត្តទុកដាក់ ជាទីបំផុតសំរាប់សាងសង់នៅលើផ្ទៃដីតូចមួយកន្លែងនិងប្រើថវិកាចំនួនតិចតួច។ តំលៃផ្ទះឈើនោះគេបានប៉ាន់គិតទៅតាម តំលៃឈើអារនៅលើទីផ្សារ សព្វថ្ងៃគឺមួយម៉ែត្រគុីគុណថ្លៃ ១២៥ ដុល្លា ។ ចំណែកផ្ទះថ្ម គេវិញត្រូវគ្រោងប្លង់ដែលមានចាក់គ្រឹះ មាំនិងថ្មសំរាប់ជួយទ្រជាន់ទី ២ ដែលត្រូវធ្វើ ទៀតនៅថ្ងៃអនាគត ។ តំលៃធ្វើផ្ទះថ្មីសាមញ្ញ មួយខ្នង បើគិតជាម៉ែត្រក្រឡាគឺ ១០០ ដុល្លាក្នុងមួយម៉ែត្រ ។ ដើម្បីបន្ថយ តំលៃសាងសង់ផ្ទះបែបនេះ ប្រជាពលរដ្ឋយើងគាត់មានយោបល់ខ្លះដូចតទៅ ជាដំបូង • សាងសង់តែ " តួផ្ទះនៅ " សិនបានហើយ ក្រុមគ្រួសារផ្ទះនោះជាអ្នកបិទ ឬលាបជញ្ជាំងរួចធ្វើឬដាក់កំរាលជាក្រោយ។ • ធ្វើជញ្ជាំងបែបសាមញ្ញធម្មតាដើម្បីកុំឱ្យចុះលុយ ។ • ប្រើកំលាំងមនុស្សក្នុងគ្រួសារជួយធ្វើដើម្បីកុំឱ្យចុះលុយជួលជាងគឺមិនចាំបាច់មានអ្នកមកពីក្រៅជួយច្រើនទេ។ • ធ្វើផ្ទះឱ្យស្របពេលគ្នាចងក្រងគ្នាជាក្រុមព្រោះត្រូវទិញសំភារៈជាដុំមិនត្រូវទិញជារាយទេ ។

# MODEL HOUSE EXHIBITION :

## Phnom Penh gets a look at People's Ideas

The two house designs made their triumphant public debut in May. Full-size models of cloth and wood were put up near the SUPF office in Basaac. Hundreds of people from around the city came to see the houses and meet the designers. Officials from the Royal Government and the Municipality also came, along with friends from NGOs and other organisations.

Both houses were designed for small plots and small budgets. The wood house was priced at current timber prices of $125 / cubic metre. The brick house has a hefty foundation and concrete frame to support a future second floor. Simple brick construction runs about $100 per square metre. Here's how the people plan to bring those rates down :

- Build only core houses now, families can plaster and finish floors later.
- Use common walls to reduce wall costs
- Trim labour bill by contributing family labour, eliminating middle men.
- Build houses in groups, buy materials in bulk.

## Wood House Costs :



**តំលៃធ្វើផ្ទះឈើ/គិតជាដុល្លាអាមេរិក** *(in US Dollars)*

| | | |
|---|---|---|
| ***Area:*** Upstairs | មានអ្វីខ្លះ មានជាន់លើ | 24 sq. metres |
| Kitchen | មានចង្ក្រានបាយ | 8 sq. metres |
| **Total Area** | សរុបទំហំ | **32 sq. metres** |
| Timber Frame, floor | ឈើអារធ្វើគ្រោងនិងក្រាល | $ 290 |
| Timber Walls | ឈើអារសំរាប់ធ្វើជញ្ជាំង | 303 |
| Roof | ដំបូល | 199 |
| Doors, windows, stairs | ទ្វារបង្អួចជណ្តើរ | 344 |
| Latrine | បង្គន់អនាម័យ | 22 |
| Labour | កំលាំងពលកម្ម | 160 |
| **TOTAL** | **សរុប** | **$ 1,314** |
| **Rate** | **អត្រាតំលៃក្នុងមួយម៉ែត្រក្រឡា** | **$41 / sq. metre** |

## Brick House Costs :



**តំលៃធ្វើផ្ទះឥដ្ឋបូក**

| | | |
|---|---|---|
| ***Area:* Full House** | ទំហំ | **24.5 sq. metres** |
| Foundation, columns, floor | គ្រឹះ សសរ កំរាល | $ 500 |
| Brick Walls | ជញ្ជាំងឥដ្ឋ | 500 |
| Roof | ដំបូល | 100 |
| Doors, Windows | ទ្វារ បង្អួច | 275 |
| Finishes | លាបថ្នាំ សំអាត | 150 |
| Latrine | បង្គន់អនាម័យ | 20 |
| Labour | កំលាំងពលកម្ម | 350 |
| **Total** | **សរុប** | **$ 1,620** |
| **Rate** | **អត្រាតំលៃក្នុងមួយម៉ែត្រក្រឡា** | **$66 / sq. metre** |

# HOW WE LIVE :

## The City Needs the Working Poor

A lot of the problems faced by the city and by the poor are put into perspective when you realize this simple relationship: ***Poor people come to the city because it offers the jobs they need; the city needs the poor for their cheap labour.***

Climb up the dark stairs of Phnom Penh's crowded buildings and you hear the rattle of sewing machines. In the streets you see people selling petrol from soda bottles, cooking soup, patching tires. In the narrow lanes of informal settlements, you pass shops selling salt, fish and sauces knotted up in tiny pastic bags. The city is filled with people working, selling, dealing.

### The Noodle Lady :

Kunthea sells noodles in front of Wat Niroth. Every morning she buys flat white noodles, fish and greens at the market. Back home, she cooks the noodles, prepares her sauces, and loads everything into a yoke she carries over her shoulder. Her customers are labourers and cyclo drivers who squat on the ground, slurping her savory noodles from china bowls. Twice a day she cooks and sells, morning and afternoon. Kunthea is one of *thousands* of self-employed noodle sellers in Phnom Penh. She makes about 5,000 Riels a day, or about US$50 a month. She lives in an informal settlement nearby in Chbar Ampouv.

This is the informal sector at work. It works like a hearty and fast-growing plant which thrives in harsh conditions, and it is doing more to develop Phnom Penh than all the foreign aid or government programmes in the world. But where do all these workers live?

Informal settlements are like piggy-banks of labour for Phnom Penh. They supply the city with thousands of workers, whose cheap labour is vital to the city's economic success, but whose wages are to small to afford decent housing. Who lives in informal settlements? Here is what SUPF found out about employment in the city's informal settlements:

### What do People do?

| | |
|---|---|
| Number of settlements surveyed | 379 settlements |
| Total population | 171,730 people |

**WOMEN'S JOBS**

| | |
|---|---|
| Total working women | 27,535 women |
| • Housewife | 26% |
| • Self-employed, small businesses | 62% |
| • Labourer | 8% |
| • Government job | 3% |
| • Private job | 1% |

**MEN'S JOBS**

| | |
|---|---|
| Total working men | 37,123 men |
| • Self-employed, small businesses | 19% |
| • Labourer | 43% |
| • Government jobs | 19% |
| • Private jobs | 3% |
| • Moto / Cyclo driver | 16% |

# យើងរស់នៅដោយរបៀបណា ទីក្រុងនេះវាត្រូវការអ្នកក្រឱ្យធ្វើការងារ

បើយើងចង់ដឹងអំពីបញ្ហាជាច្រើន ដែលមាននៅក្នុងទីក្រុងយើងចាំបាច់ត្រូវយល់ អំពីទំនាក់ទំនងសាមញ្ញធម្មតានេះជាមុនសិន អ្នកក្រីក្រគេមកនៅតាមទីក្រុងពីព្រោះ គេត្រូវមករកការងារធ្វើ ។ គឺទីក្រុងត្រូវការអ្នកក្រឱ្យមកធ្វើការងារព្រោះថាឈ្នួលសំរាប់អ្នកក្រវាថោក ។មនុស្សគ្រប់ៗរូបរស់នៅភ្នំពេញសុទ្ធតែប្រកបមុខរបរការងារផ្សេងៗ។ នៅតាមទីប្រជុំជនដែលមានមនុស្សច្រើនកកកុញយើងនឹងបានឮសម្លេងម៉ាស៊ីនដេរទ្រហ៊ឹង។ រីឯនៅតាមដងវិថីនានាវិញយើងនឹងបានឃើញ មនុស្សលក់ ប្រេងសាំង លក់បបរ ប៉ះកង់ឡាន ម៉ូតូ ។ល។ នៅតាម សំណង់តូចៗបែបអណាធិបតេយ្យ យើងនឹងឃើញមានកន្លែងលក់អំបិល លក់ត្រី លក់ទឹកត្រី ដែលគេច្រក ថង់តូចៗ ។

**ស្ត្រីអ្នកលក់នំបញ្ចុក** : នាងគន្ធាជាអ្នកលក់នំបញ្ចុកនៅមុខវត្ត និរោធន៍ ជារៀងរាល់ព្រឹកនាងតែងតែទៅទិញនំបញ្ចុក ទិញត្រី បន្លែ នៅផ្សារ។ នៅផ្ទះ នាងធ្វើទឹកសម្លរនំហើយរៀបចំរបស់របរសព្វគ្រប់បែបយ៉ាងដាក់សង្រែក រួចរែកដើរលក់។ អ្នកដែលទទួលទាននំបញ្ចុករបស់នាងមានកម្មករនិងអ្នកធាក់ស៊ីក្លូ។ ពួកគេច្រើនអង្គុយពែន ភ្នែន លើដីផ្ទាល់ទទួលទាន នំបញ្ចុកដ៏ឆ្ងាញ់របស់នាងដែលចាប់ដាក់ចានគោមតូចៗ ។ ក្នុងមួយថ្ងៃៗនាងត្រូវ ដាំទឹកសម្លនំ និង ដើរលក់ពីរដង។ នាងគន្ធាជានារីម្នាក់ក្នុងចំណោម នារីរាប់ពាន់នាក់ដែល ដើរលក់នំបញ្ចុកដោយខ្លួនឯងនៅក្នុងទីក្រុងភ្នំពេញ ។ នាងអាចចំណេញប្រាក់បានប្រហែលជា ៥.០០០រៀលក្នុងមួយថ្ងៃៗបបានប្រហែល ៥០ដុល្លាក្នុងមួយខែៗ។ នាងមានទីលំនៅៗសំណង់ អណាធិបតេយ្យជិតៗនេះគឺ នៅច្បារអំពៅ។

នេះគឺជាប្រភេទការងារ មួយអាចឱ្យមនុស្សយើង រកប្រាក់ចំណូលបានតិចតួច ។ វាជាការងារដែលជួយធ្វើឱ្យអភិវឌ្ឍន៍ទីក្រុងជាងទទួលអំណោយពីបរទេសឬពីកម្មវិធីរបស់រដ្ឋ។ ប៉ុន្តែតើអ្នកទាំងនេះនឹងត្រូវរស់នៅទីណាបាន? សំណង់អណាធិបតេយ្យ គឺដូចជាកូនជ្រូកសំរាប់ដាក់សន្សំកំលាំងពលកម្មមនុស្សធ្វើការឱ្យទីក្រុងភ្នំពេញ ព្រោះថាសំណង់ទាំងឡាយនោះអាចផ្តល់កំលាំងមនុស្ស ឬ កម្មកររាប់រយពាន់នាក់ឱ្យធ្វើការងារសំរាប់ទីក្រុងដំណើរការ ។ កំលាំងពលកម្មរបស់អ្នកទាំងនេះវាចាំបាច់ណាស់សំរាប់នាំឱ្យសេដ្ឋកិច្ចទីក្រុងបានសំរេចជោគជ័យ ប៉ុន្តែ ប្រាក់ដែលគេរកបានមកនោះវាមានចំនួនតិចតួចពេកដែលមិនអាចយកទៅធ្វើផ្ទះសម្បែងល្អបាន ។ តើនរណាគេដែលរស់នៅតាមសំណង់អណាធិបតេយ្យទាំងនេះ? នេះហើយដែលអង្គការ SUPF បានរកឃើញអំពីការងារ នៅតាមសំណង់អណាធិបតេយ្យនៅក្នុងទីក្រុងភ្នំពេញ ។

**តើមនុស្សទាំងនេះគេធ្វើអ្វីខ្លះ ?**

| | |
|---|---|
| ចំនួនផ្ទះអណាធិបតេយ្យដែលយើងបានធ្វើអង្កេត | ៣៧៩កន្លែង |
| ចំនួនប្រជាជនសរុបនៅតាម | ១៧១.៧៣០នាក់ |
| **ការងាររបស់នារី** ចំនួននារីធ្វើការងារ | ៣៧.៥៣៥ នាក់ |
| ធ្វើមេផ្ទះ ឬ នៅផ្ទះ | ២៦ % |
| លក់ដូរខ្លួនឯង លក់កំប៉ិកកំប៉ុក | ៦២ % |
| ធ្វើជាកម្មករប្រើពលកម្ម | ៨ % |
| ធ្វើការរាជការ | ៣ % |
| ធ្វើការងារឯកជន | ១ % |
| **ការងាររបស់បុរស** ចំនួនបុរសធ្វើការងារ សរុបមាន | ៣៧.១២៣ នាក់ |
| លក់ដូរខ និង លក់កំប៉ិកំប៉ុក | ១៩ % |
| ធ្វើជាកម ករប្រើពលកម | ៤៣ % |
| ធ្វើការរាជការ | ១៩ % |
| ធ្វើការងារឯកជន | ៣ % |
| រត់ម៉ូតូឌុប និង ធាក់ស៊ីក្លូ | ១៦ % |



***Painting clay piggy banks for sale in the city's markets** - the mother uses her hand to smear on the red and yellow glazes, while the children decorate them with flowers and flourishes. Don't let anyone tell you this hard-working family is not a vital part of the city's success story.*



*This is Tho Thary's house in Toek La'ok roadside settlement. Small and carefully crafted - it follows all the rules of traditional Cambodian building wisdom. Until you've sat on the smooth floorboards in the cool interior, it's hard to imagine how delightful such houses can be.*

# យើងរស់នៅយ៉ាងដូចម្តេច ផ្ទះដូចជាឆ័ត្រ

ពេលអ្នកមកពីប្រទេសក្រៅមកដល់ប្រទេសកម្ពុជាដំបូង ពួកគេច្រើនមានអារម្មណ៍រីករាយចូលចិត្តខ្លាំងដោយ សារបានឃើញផ្ទះរបស់ប្រជាជនកម្ពុជា ព្រោះថាផ្ទះទាំងឡាយច្រើនធ្វើខ្ពស់ពីដីមានជើងសសរវឹងមាំទ្រពីក្រោម និងមានដំបូលមើលទៅដូចជាស្លាប។ យើងបានឡើងផ្ទះនោះតាមជណ្តើររាងចោត រួចហើយទទួលទាន ទឹកតែពេលយើងអង្គុយនៅលើក្តារក្រាលផ្ទះដែលមានសភាពរលោងស្រិល ។ ជុំវិញផ្ទះមានដើមដូងដើមខ្នុរ នឹងមានសត្វមាន់ដើរនៅពីខាងក្រោមផ្ទះហើយមានកូនង៉ាដេកក្នុងអង្រឹង។ ផ្ទះទាំងនេះធ្វើឡើង ដូចជាផ្ទះនៅក្នុងរឿង ព្រេងសំរាប់កុមារមើលអញ្ជើដែរ។

**មានទេសចរណ៍ម្នាក់មកពីប្រទេសឥណ្ឌាបាននិយាយថា :**
**"ផ្ទះជនជាតិឥណ្ឌា ធ្វើដូចជាបន្ទាយទាហាន រីឯផ្ទះរបស់ជនជាតិខ្មែរធ្វើដូចជាឆ័ត្រ "**

នៅតំបន់អ្នកក្រីក្រ គំនិតនិយាយអំពីការសាងសង់ផ្ទះនេះនៅតែមានជាបន្តរហូតមក ។ ឈើដែលគេធ្វើនោះអាចមានសភាពស្តើងជាង ឬគគ្រើមជាង ហើយដំបូលវិញអាចធ្វើពីស្លឹកត្នោតដែលមិនមែនជាក្បឿង ប៉ុន្តែ បើនិយាយពីគំនិតសាងសង់វិញគឺដូចគ្នាទាំងអស់ ។ នេះពុំមែនចោទឡើងដោយសារបញ្ហាថា ប្រជាពលរដ្ឋខ្មែរគឺជាអ្នក មានមនោសញ្ចេតនាខ្លាំងទៅលើប្រពៃណីរបស់ខ្លួននោះឡើយ ប៉ុន្តែផ្ទុយមកវិញគឺមកពីគេមានហេតុផលល្អ ទៅវិញទេដែលនាំឱ្យគេធ្វើផ្ទះបែបនេះ ។

- សសរផ្ទះនៅពីខាងក្រោមផ្ទះនោះវាជាអ្នកធ្វើឱ្យផ្ទះស្ថិតនៅខ្ពស់ពីដី ឬ ទឹកនៅពេលមានភ្លៀងជន់លិច ។ នៅពីក្រោមផ្ទះវិញ គេអាចមានកន្លែងសំរាប់ដេកពួនទៀតនៅរដូវប្រាំង ឬ រដូវក្តៅព្រោះនៅខាងក្រោមវាត្រជាក់ជាង។
- ញ៉ាំង និង បង្អួច ជួយធ្វើឱ្យមានខ្យល់ចេញចូលនៅរដូវក្តៅ និង ពេលមានធាតុអាកាសត្រជាក់ ។
- ឈើមានតម្លៃថោកជាងឥដ្ឋឬថ្ម ងាយស្រួលពេលធ្វើ ព្រមទាំងស្រួលរកជាងធ្វើទៀតផង។
- ដើមឈើនៅជុំវិញផ្ទះ ដូចជាដូង-ឈើហូបផ្លែឯទៀតៗ ជួយជាម្លប់ដល់ផ្ទះ ។
- ដំបូលផ្ទះគេធ្វើឱ្យមានកន្លែងត្រងយកទឹកភ្លៀង បានដោយគេត្រូវបញ្ចូលទឹកនោះក្នុងពាងឬអុងសំរាប់ផឹក និងបោកគក់ផ្សេងៗ ។

រៀងរាល់ឆ្នាំទឹកជំនន់ ចេះតែខ្លាំងទៅៗ ហើយជារៀងរាល់ឆ្នាំដីដែលជាជ្រោយច្រាំងមាត់ទន្លេ ត្រូវរលាយហូរទៅតាមទឹកជានិច្ច។ ប្រជាជនដែលរស់នៅតាមច្រាំងទន្លេក្នុងបរិវេណទីក្រុងភ្នំពេញច្រើនជួបប្រទះបញ្ហាបន្ថែមមួយទៀតដែល អ្នកខ្លះចាំបាច់ត្រូវតែរើរុះផ្ទះទៅនៅកន្លែងផ្សេង ដូច្នេះផ្ទះ ឈើអាចងាយស្រួលជាង ។

**ផ្ទះដែលងាយរើរុះផ្លាស់ទីកន្លែង**

យ៉ាន ស៊ូម៉ៃ គាត់រស់នៅជាប់ច្រាំងទន្លេសាបក្នុងសង្កាត់ច្បារអំពៅ ។ គាត់តែងរើរុះផ្លាស់កន្លែងផ្ទះគាត់ជាញឹកញាប់ ដោយសារច្រាំងទន្លេបាក់ដី។ គាត់ច្រើនរើផ្ទះម្តងមួយផ្ទាំងៗរួចដាក់ផ្គុំគ្នាវិញនៅទីតាំងថ្មី ឥឡូវនេះគាត់បានបាញ់ថ្នាំដាក់លេខស្រួលចំណាំដាក់លើសសរ និងឈើសំខាន់ៗ ។

# HOW WE LIVE :

## " Houses like Umbrellas "

Anyone who comes to Cambodia for the first time cannot help but be charmed by the wooden houses Cambodians build. They are built on stilts of precious hardwoods, with tiled rooftops ornamented with wing-like figures at the corners. Their stairs are steep as ladders, their polished floorboards have gaps between, big enough to push a cigarette butt through. Coconut palms and jackfruit trees surround them, chickens scuffle between the columns, babies sleep suspended in hammocks. *They are like houses designed for a fairy tale.*

**A visitor from India made this observation : *"Indian houses are built like fortresses, Khmer houses are built like umbrellas."***

In poor settlements, all this magical wisdom about housebuilding fully survives. The wood may be thinner or more roughly planed, the roof may be palm thatch instead of tiles, the floors may be split bamboo instead of gleaming planks, but the idea is the same. This is not because Khmer people are all sentimentalists (although many are!), but because there is good sense behind these designs. These houses help poor people survive in flood-prone corners of the city where nobody else wants to live.

- The stilts keep houses above flood waters during the rains, double living space, and provide cool shade underneath during the hot season.
- Their airy, perforated walls and louvered windows catch breezes and allow plenty of air circulation in Cambodia's sticky, tropical climate.
- Wood is still cheaper than brick, easier to build with and all the fine carpentry skills survive
- Thick trees around the house provide cooling shade, as well as coconuts and fruit.
- Those delightful winged roofs are designed not to *shed* rainwater, but to *catch it* between their gables and channel it into pots down below, for drinking and washing.

Every year, the floods in the Mekong Delta get worse, and every year more land is lost to the rivers through erosion of their banks. Phnom Penh is criss-crossed by rivers. For many who live along their edges, yearly shifting of their houses is a tiresome and expensive necessity, but made easier by wooden house-building systems.

**Portable Houses :**

Yan Sumai lives on a high bluff along the Tonle Sap River, in Chbar Ampou. She has had to move back from the eroding river banks many times. She and her sons have taken apart her wooden house, moved it, and put it back together again *so many times* that they have now painted number codes on all the columns and beams to streamline the operation.

# BACK TO THE OLD LAND PROBLEM AGAIN :

## Location is Critical to the Lives of the Urban Poor . . .

Relocation is a strategy many cities use to clear unwanted settlements. But moving poor families to remote parts of the city never works. In one relocation project, the city aquired land at Kop Sreou and divvied it up between families evicted from squatter settlements in the city. The project offered "free land and free houses." Never mind that the land was flooded for half the year and 20 kms from the city centre.

A year later, 70% of the 506 houses in Kop Sreou had been abandoned or sold. People couldn't find work, schools were far away, transport costs were high. So they moved back to informal settlements in the city. Now, the muncipality is trying the same thing again at Toul Sambo, but is having trouble finding takers for the free plots, which most consider too far away.

The problem is not with relocation *per se*, but with the poor being excluded from planning the projects. If communities had been asked what they thought about the sites, anybody would have said the land was hopeless and too far away. These projects miss two important facts:

**1** ***Location is crucial :*** Poor people have good reasons for living where they do. Their communities offer support structures of friends and relatives. Living close to jobs and schools cuts the expense of transportation. The minute these factors disappear, the delicate survival formula breaks down.

**2** ***No such thing as free land :*** Projects like these are never *free*. People give up houses and land *which they paid for*, and leave behind vital sources of income. The city is not giving anything away but only exchanging land for land.

### Nobody gets land for free :

Bopha lives in T-86, where she sells vegetables and fish. She came to Phnom Penh in 1993 from a refugee camp on the Thai border. The UN gave her a small resettlement allowance, which she put together with her savings to buy 20 square metres of land for $1,500 from a soldier who had been alloted the plot. Then she built a simple wooden house for about $1,000. That comes to $2,500 - a hefty investment for a family earning less than $70 a month.

***But what if the poor were involved? What if they selected the relocation sites and helped plan out the scheme?*** Last year, several SUPF communities teamed up with USG and the UNCHS to do just that. They combed the city, looking for open land that was high enough to be out of the floods, and close to jobs and schools. They identified five sites and are now negotiating with the Municipality about aquiring the land for the resettlement of several roadside communities. One site in particular, near Wat Samboor Meas, is everybody's favorite and has become the centre of their planning.



*Nobody lives here. This is the main road in the resettlement scheme at Kop Sreou, lined with hcuses that have been abandoned, because they are too far from jobs and schools, not to mention being submerged in floodwaters for half the year.*

# បញ្ហារបស់បញ្ហាដីធ្លី សារៈសំខាន់នៃទីតាំងលំនៅ

នៅតាមបណ្ដាទីក្រុងនានាភាគច្រើនគេច្រើនប្រើគំរោងកម្មវិធី ប្ដូរទីតាំងលំនៅសំរាប់យកអ្នកមាន លំនៅអនាធិបតេយ្យ ចេញពីកន្លែងមួយដែលរដ្ឋត្រូវការ ប៉ុន្តែការដែលគេបញ្ជូនអ្នកក្រីក្រឱ្យទៅរស់នៅតាមតំបន់ ដាច់ស្រយាលពីទីក្រុងនោះគេពុំ ដែលធ្វើបានសំរេចឡើយ ។ សាលាក្រុងធ្លាប់បានប្រើដីនៅតំបន់ កប់ស្រូវ ធ្វើជាទីតាំងលំនៅថ្មីដែលគេមានក្នុងគំរោងមួយ ។ គេបានបែងចែកដីមួយឡូត៍ប្រគល់ឱ្យទៅក្រុមគ្រួសារ ប្រជាពលរដ្ឋដែលត្រូវបានបណ្ដេញចេញពីតំបន់អនាធិបតេយ្យនៅក្នុងទីក្រុង។គំរោងកម្មវិធីនោះគេបានឱ្យដីនិងឱ្យផ្ទះទៅប្រជាពលរដ្ឋ "ទទេរដោយឥតគិតថ្លៃ" តែដីនោះជាដីទំនាបមានទឹកជក់ លិចរយៈពេលកន្លះឆ្នាំ ក្នុងមួយឆ្នាំៗហើយស្ថិត នៅចម្ងាយប្រមាណ១៥គីឡូម៉ែត្រ ពីកណ្ដាលនៃទីក្រុង។

រយៈពេល ១ ឆ្នាំក្រោយមក ចំនួន៧០%នៃផ្ទះ៥០៦ខ្នងនៅតំបន់កប់ស្រូវ នោះបានត្រូវប្រជាពលរដ្ឋដែលជាម្ចាស់បោះបង់ឬលក់ចោល។ ប្រជាពលរដ្ឋនៅទីនោះមិនអាចរកការងារធ្វើបានរីឯសាលារៀនវិញក៏នៅឆ្ងាយ ហើយតម្លៃដំណើរក៏ថ្លៃទៀត ។ ដូច្នេះ ប្រជាជនទាំងនោះក៏ត្រូវតែត្រឡប់មកនៅតាមតំបន់ អណាធិបតេយ្យក្នុងទីក្រុងវិញជាថ្មីទៀត ។ ឥឡូវនេះ សាលាក្រុងកំពុងតែខិតខំអនុវត្តដូចមុនទៀត នៅទួលសំបូរណ៍ តែគេមិនឃើញមានគ្រួសារណាចង់រើទៅនៅទីនោះទេ ព្រោះវានៅឆ្ងាយដាច់ពីទីក្រុងពេក ។ ការរើរុះផ្លាស់ប្ដូរផ្ទះឬតាំងទីលំនៅថ្មីនោះវាគឺជាគំនិតមួយល្អហើយ តែអ្វីដែលជាបញ្ហានោះនៅត្រង់ថាការធ្វើ គំរោង កម្មវិធីនោះយើងមិនបានឱ្យប្រជាជនចូលរួមចំណែកផង។ គ្មាននរណាម្នាក់សាកសួរប្រជាឱ្យដឹងថាតើ គេគិតយ៉ាងណាដែរអំពីទីកន្លែងថ្មីនោះ ព្រោះថាបើយើងសួរប្រជាជន អាចមានអ្នកណាម្នាក់និយាយឱ្យយើង ដឹងបាន ថាដីនោះគេពិបាករស់នៅហើយនៅឆ្ងាយទៀតផង ។ ដូច្នេះគំរោងកម្មវិធីនេះនៅខ្វះខាតពីរចំណុច

**១-ទីតាំងលំនៅស្ថានវាមានសារសំខាន់ :** ប្រជាពលរដ្ឋដែលក្រីក្រគេច្រើនមានហេតុផលល្អសំរាប់ជីវិតរស់នៅរបស់គេនៅត្រង់ទីកន្លែងដែលគេរស់នៅ ។ បណ្ដាសហគមន៍ត្រូវជួយគាំទ្រនិង ផ្ដល់ជំនួយដល់ប្រជាពលរដ្ឋដែលគាត់មិន មានលុយកាក់ និង អំណាច ។ ប្រជាពលរដ្ឋទាំងនេះគាត់គ្មានប្រាក់ច្រើនសំរាប់ជិះទេ ពួកគាត់ចាំបាច់ត្រូវនៅជិតការងាររបស់គាត់ នៅជិតទីផ្សារ និង នៅជិតសាលាកូនគាត់រៀន ។

**២-គ្មានរឿងដែលថាប្រជាជនបានទទួលដីដោយមិនអស់ប្រាក់នោះឡើយ :** គំរោងកម្ម វិធីបែបនេះមិនមែនឱ្យដីប្រជាពល ទទេរៗនោះទេព្រោះថាប្រជាពលរដ្ឋគាត់បានបោះបង់ចោលដីផ្ទះ សម្បែងរបស់គាត់ដែល គាត់បានទិញ ហើយនិង ត្រូវទៅឆ្ងាយពីមុខ របររបស់គាត់ដែលគាត់ធ្លាប់រក ចំណូលបាន ចិញ្ចឹមជីវិតនោះថែមទៀតផង ។ ដូច្នេះមានន័យថាសាលាក្រុងមិនបានឱ្យអ្វីទៅប្រជាពលរដ្ឋនោះទេគឺសាលាក្រុង គ្រាន់តែដូរដីឱ្យប្រជាជនទៅនៅទីតាំងនិងផ្សេងប៉ុណ្ណោះ "គឺជាការដូរដីគ្នាជាមួយប្រជាជន " ទេវិញទេ ។

**គ្មាននរណាបានដីមកទទេរៗនោះទេ** នាងបុប្ផារស់នៅក្នុងសំណង់ តេ-៨៦ ហើយនៅទីនោះនាងរកស៊ីលក់បន្លែនិងត្រី។ នាងបានមកនៅទីក្រុងភ្នំពេញកាលពីឆ្នាំ ១៩៩៣ ពេលដែលនាងត្រឡប់មកពីជំរំ ជនភៀសខ្លួនតាមជាយដែនថៃវិញ។ ពេលនោះអង្គការសហប្រជាជាតិបានឱ្យប្រាក់នាងបន្តិចបន្តួចសំរាប់សង់ផ្ទះនៅ។ នាងបានយកប្រាក់ នោះនិងប្រាក់ដែល នាងសន្សំបានទៅទិញដីមួយកន្លែងទំហំ ២០ ម៉ែត្រក្រឡាបួនជ្រុងក្នុងតម្លៃ ១.៥០០ដុល្លា ពីយុទ្ធជនម្នាក់ដែលជាអ្នកកាន់កាប់ដីនោះជាកម្មសិទ្ធ ។បន្ទាប់ពីបានដីហើយនាងក៏ធ្វើជាផ្ទះឈើធម្មតាមួយអស់ប្រាក់ប្រហែល ១.០០០ ដុល្លាទៀត។ ដូច្នោះប្រាក់ដែលនាង ចំណាយទាំងអស់គឺ ២.៥០០ ដុល្លាសំរាប់ដី និង ផ្ទះនោះ ។ ប្រាក់ចំនួននេះវាច្រើន ណាស់សំរាប់គ្រួសារមួយដែលរកប្រាក់ចំណូលបានក្នុងមួយខែមិនដល់៧០ដុល្លានោះ ។

តើវានឹងទៅជាយ៉ាងណាទៀតបើប្រជាជនក្រីក្រខ្លួនឯងបានជ្រើសរើសទីកន្លែងនិងមានគំរោងសំរាប់គំកម្មវិធីតាំងទីលំនៅថ្មីរបស់គេនោះ ? កាលពីឆ្នាំទៅមិញមានសំណង់តាមផ្លូវមួយចំនួនក្នុងគំរោងស.ស.អ.កបានធ្វើការងារនេះជាមួយគំរោងកម្មវិធីអង្គការសហប្រជាជាតិមួយ ។ ពួកគេបានដើររកដីវាលដែលស្ថិតនៅទីរាងខ្ពស់បន្តិចដើម្បីកុំអោយទឹកលិចបាន ហើយត្រូវឱ្យនៅជិតការងារនិងសាលារៀន។ ពួកគេបានរកឃើញដីប្រាំកន្លែងហើយឥឡូវនេះពួកគេកំពុងតែធ្វើការងារនេះជាមួយអង្គការ ហើយនឹងជាមួយសាលាក្រុងដើម្បីឱ្យបានដីនោះមកក្រុមគ្រួសារសំណង់នៅតាមផ្លូវថ្នល់នេះ។



*On the last night of the visit, a send-off party was thrown for the Philippines visitors at the SUPF office. Friendships between people from poor settlements in different parts of the world leads to benefits of many sorts, and they're also fun.*

# ការប្តូរបទពិសោធន៍គ្នារបស់សហគមន៍

**ចំណាប់អារម្មណ៍របស់អ្នកទេសចរណ៍មកពីតំបន់តុងដូនៃប្រទេសហ្វីលីពីន** តំបន់តុងដូ ជាតំបន់សំណង់អណាធិបតេយ្យ ធំជាងគេមួយនៅទីក្រុងម៉ានីលនៃប្រទេសហ្វីលីពីន។ ថ្មីៗកន្លង ទៅនេះ មានសមាជិកមួយក្រុម របស់សហគមន៍ក្រីក្រមកពីតំបន់តុងដូ បានមកធ្វើទស្សនៈកិច្ចនៅទីក្រុងភ្នំពេញ ហើយគេបានធ្វើការងារពីរអាទិត្យជាមួយអង្គការ SUPF។ ពួកគេបានទៅនៅជាមួយគ្រួសារក្រីក្រ ដែលរស់នៅតាមទន្លេបាសាក់ ហើយនៅទីនោះគេ បានចូលរួមប្រជុំនិង បានឃើញក្រុមសន្សំប្រាក់របស់ SUPFធ្វើការងារ ។ មុនពេលពួកគេត្រូវត្រឡប់ទៅវិញពួកប្រជាជននៅតំបន់នោះនាំគ្នាអង្គុយជុំគ្នា ហើយអ្នកទេសចរណ៍ទាំងនោះក៏បានរ៉ាយរ៉ាប់នូវរឿងរ៉ាវជា ច្រើនប្រាប់ពួកគេ ឱ្យដឹងអំពីអង្គការ SUPF ដែលកំពុងតែណែនាំពួកគេនេះ ។ តទៅនេះជាខ្លឹមសារខ្លះៗដែលពួកគេមាន:

១ សហព័ន្ធរបស់អ្នកធ្វើការងារខ្លាំងណាស់ ក្នុងការនាំមនុស្សឱ្យធ្វើការងាររួមគ្នា ធ្វើការងារតាមវិធីផ្សេងៗជាច្រើននិង ជាមួយមនុស្សផ្សេងៗគ្នាជាច្រើននេះ ។ មនុស្សគ្រប់ៗរូបសុទ្ធតែបានរៀនសូត្រពីការងារនេះ ហើយគេនឹងក្លាយទៅជា មានស្មារតីខ្លាំងក្លាមិនខាន ។

២ ទាំងសមាជិកនិងទាំងមេដឹកនាំនៃអង្គការ SUPFនេះធ្វើការងារបានស្រុះស្រួលគ្នាល្អណាស់ ។ ពួកគេសុទ្ធតែយល់ដឹងពីមុខងារ និងតួនាទីរបស់គេរៀងខ្លួន ហើយដោយសារតែពួកគេជួយគាំទ្រ គ្នាទៅវិញទៅមកនេះហើយ ទើបធ្វើឱ្យសហព័ន្ធនេះរស់បាន ។

៣ អ្នកធ្វើការងារផ្សេងៗច្រើនបែបច្រើនយ៉ាងបែបជាសហព័ន្ធមួយហើយដោយសារការងារនេះ ហើយទើប អ្នកអាចឆ្លើយតបទៅនឹងរាល់បញ្ហាទាំងអស់ដែលអ្នកក្រីក្រនៅក្នុងសហព័ន្ធនេះកំពុងតែជួបប្រទះ ។ ទន្ទឹមនេះបណ្តាសហគមន៍ទាំងឡាយនឹងមើលឃើញតម្លៃការងារនៃសហព័ន្ធដ៏ធំបែបនេះ ។

៤ អ្នកក្របានបង្ហាញភស្តុតាងឱ្យថា អ្នកក្រីក្រពិតជាមានលទ្ធភាពអាចសន្សំប្រាក់បានមែន ។ ប្រជាជនប្រាកដជាអនុវត្តការសន្សំប្រាក់បានបើគេឃើញថាការធ្វើយ៉ាងនោះអាចនាំឱ្យគេមានការរីកចំរើនក្នុងជីវិត គេ។

៥ ឯកសារស្តីពីការសន្សំប្រាក់និងផ្នែកឥណទានរបស់អ្នកពិតជាថែរក្សាបានល្អហើយមើលងាយយល់ទៀតផង ។ អ្នកណាក៏អាចពិនិត្យមើលបានស្រួលដែរប្រការនេះហើយដែលធ្វើឱ្យគេទុកចិត្តបាន ។

៦ អ្នកបានបង្ហាញពួកយើងឱ្យដឹងថា ជាការមួយល្អដែលយើងត្រូវឱ្យប្រជាពលរដ្ឋ *ខ្ចីប្រាក់ចំនួនតិចតួច* ហើយ *មានរយៈពេលខ្លី*។ វិធីនេះអាចធ្វើឱ្យយើងមានប្រាក់រហូតសំរាប់ឱ្យសមាជិក*គ្រប់ៗរូប* ខ្ចីពេលដែលគេត្រូវការ។

៧ អ្នកមានសមត្ថភាពអាចធ្វើការងារបានដោយខ្លួនឯងហើយ គឺជាអង្គការមួយរបស់ប្រជាពលរដ្ឋ។ អ្នកមិនត្រូវរង់ចាំឱ្យអ្នកណាម្នាក់ផ្សេងមកចាប់ផ្តើមជំហ៊ានទី ១ នោះឡើយ ហើយអ្នកក៏មិនចាំបាច់ រង់ចាំទទួលជំនួយពីអ្នកក្រៅសិនទើបមានដំណើរការទៅមុខនោះដែរ ។

៨ អង្គការ SUPF គោរពដល់មេដឹកនាំឯទៀតៗនៅក្នុងបណ្តាសហគមន៍ដូចជាប្រធានខ័ណ្ឌ-ប្រធានសង្កាត់ ជាដើមហើយព្រមទាំងបានសហការធ្វើការងារជាមួយគេទៀតផង។ ការធ្វើដូច្នេះបានវាអាចជួយអ្នកឱ្យ កសាងទំនាក់ទំនង ជិតស្និតជាមួយថ្នាក់អភិបាលក្រុងហើយនិង អាចជាស្ពានសំរាប់បណ្តាក្រុមនានាដែលធ្វើ ការងារផ្សេងៗពីគ្នាផងដែរ។

៩ បណ្តាអ្នកដឹកនាំសហគមន៍និងសមាជិកសហគមន៍ក្នុងអង្គការ SUPF បានទទួលស្វាគមន៍ពួកយើងដែលចាប់អារម្មណ៍ចង់រៀនសូត្របទពិសោធន៍ពីពួកគេ ។

# COMMUNITY EXCHANGES :

## Here are a few impressions from some recent visitors from Informal settlements in Tondo, Philippines . . .

Tondo is Manila's largest and most famous informal settlement, in the Philippines. A group of poor community members from Tondo visited Phnom Penh recently and spent two weeks with SUPF. They are part of *SAPSPA*, the Association for Appropriate Housing of San Pablo Apostle, in Tondo. They stayed with poor families in Basaac, attended meetings and saw how SUPF savings groups operate. Just before they left, everyone sat down together, and the visitors described many things about SUPF which inspired them. Here are some items from their list :

**1** Your federation works hard to bring people together, to work in many different ways and from different circles. Everyone learns from this, and become stronger in spirit.

**2** The members an leaders in SUPF work well together. They understand their separate responsibilities to each other. Because they support each other, the federation survives.

**3** You do lots of different kinds of work as a federation. Because of this, you are able to respond to all the problems poor people in the federation face, and communities see the value of forming large federation.

**4** You have proven to us that it ***is possible for the poor to save***. People do save when they see how it can make clear improvements in their lives.

**5** Your savings and credit records are well kept and easy to understand. Everyone can check them out, and that helps build trust and confidence.

**6** You have shown us that it is better to give credit in ***small amounts*** for ***short periods***. That way, the money can continue to circulate and be available for ***all*** members who need to borrow.

**7** You are always ready to start things on your own, as a people's organisation. You don't wait for somebody else to take the first step. You don't wait for outside help before you move.

**8** SUPF respects other leaders in the communities, like Khan and Sangkat chiefs, and works with them. That way, you build partnerships with city government and bridges between different groups.

**9** The leaders and community members in SUPF have made an open welcome to those of us who are interested in learning from your experiences.

# CONTACTS :

## SUPF

**Squatter and Urban Poor Federation**
**Hin Raleen, Pa Sovanna, Men Chamnan**
Sisowath Boulevard, Village 14
Sangkat Tonle Basaac, Phnom Penh, Cambodia
Tel. (c/o Kenneth Fernandes) 855 23 720 417
Tel. (c/o) Tuy Someth) 855 23 362 585

## ACHR - Cambodia

**Asian Coalition for Housing Rights**
**Kenneth Fernandes**
Post Box 2242,
Phnom Penh 3, Cambodia
Tel / Fax 855 23 720 417
Email: usg@pactok.peg.apc.org

## ACHR - Secretariate

**Somsook Boonyabncha, Maurice Leonhardt**
73 Soi Sonthiwattana 4
Ladprao Road, Ladprao 110
Bangkok 10310, Thailand
Tel. (622) 538 0919 / Fax (622) 539 9950
Email: maurice@ksc.9.th.com

## NSDF / Mahila Milan

**National Slum Dwellers Federation**
**A. Jockin, President**
Byculla Area Resource Centre
Meghraj Sethi Marg
Municipal Dispensary
Byculla, Mumbai 400 008, INDIA
Tel. (022) 309 6730

## SPARC

**Society for Promotion of Area Resource Centres**
**Sheela Patel, Celine D'Cruz**
Post Box 9389
Mumbai 400 026, INDIA
Tel / Fax (022) 285 1500
Email: Admin@sparc.ilbom.ernet.in

## SAHPF

**South African Homeless People's Federation**
**c/o Joel Bolnik, Mama Iris, People's Dialogue**
PO Box 34639, Groote Schuur 7937
Capetown, SOUTH AFRICA
Tel (021) 47-4740 Fax (021) 47-4741
Email: dialogue@sprintlink.co.za



***Keep your eye on this proud family in Toek La'ok roadside settlement**. The next time you see them, they may be living in a new house they built themselves, in a community they laid out themselves, on land that is their own.*

***High Spirits** is the newsletter of the Squatter and Urban Poor Federation. It was produced in Phnom Penh, with big thanks to Somaly, Nay, Kosal, and Sovanna for translation, to Marady and You at CABS for production assistance, to the staff of Ponleu Khmer and the monks at Wat Sampou Mea for workshop space, to Shiva for all-around hospitality, to Pi Chunthy, Jonathan, May and Mike at UNCHS for support on many fronts, to Robert, Declan and the students of the Faculty of Architecture for helping out with house design training, and to everybody in SUPF. **High Spirits** was printed at JSRC Printing House.*
***Copyright May, 1997.***